# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីការប្រៀបធៀបហេតុផលរបស់ព្រះពុទ្ធសាសនា ជាមួយនិងវិទ្យាសាស្ត្រ

web site: hoksavann.org

ថ្ងៃទី១ មករា ២០០៦

ហេតុផលរបស់ព្រះពុទ្ធសាសនា ជាហេតុផលមានកំរឹតខ្ពស់ មាននិយាយទាំងរូបធម៌និងនាមធម៌ តាំងលោកិយសច្ចៈទាំងលោកុត្តរសច្ច ។ ចំណែកហេតុផលរបស់វិទ្យាសាស្ត្រភាគច្រើន និយាយហេតុផលផ្នែករូប ហើយជាលោកិយសច្ច ។

ហេតុផលរបស់វិទ្យាសាស្ត្រផ្នែករូបវិទ្យា សិក្សាអំពីផ្នែករូបនិងគីមីវិទ្យា សិក្សាអំពីការផ្សំធាតុ មានហេតុផលពិតទៅតាមរូបធាតុជាលោកិយសច្ច ។ ការផ្សំធាតុសំរាប់ផលិតគ្រឿងបរិភោគដូចជាចំណីអាហារបរិភោគគ្រប់បែបយ៉ាង, ផលិតគ្រឿងប្រើប្រាស់គ្រប់បែប ដូចជាប្រដាប់ដើរដោយម៉ាស៊ីនជាដើម, ផលិតថ្នាំពេទ្យគ្រប់ប្រភេទសំរាប់ព្យាបាលរោគ និងផលិតសំលៀកបំពាក់សំរាប់ស្លៀកពាក់ជាដើម ។ នេះជាហេតុផលរបស់វិទ្យាសាស្ត្រផ្នែករូបធាតុ សំរាប់បំរើសង្គមមនុស្ស គួរឲ្យកោតសរសើរណាស់ ប៉ុន្តែគួរឲ្យរិះគន់ ចំពោះការលូតលាស់វិទ្យាមួយផ្នែកទៀត ធ្វើឲ្យលោកវិនាស គឺការបង្កើតកាំភ្លើងគ្រាប់បែកគ្រប់ធុន រហូតបង្កើតគ្រាប់បែកបរមាណូប្រល័យលោកថែមទៀត ។ ផ្នែកចិត្ត ក្រុមវិទ្យាសាស្ត្របានលើកយកមកសិក្សាដែរហៅថាចិត្តវិទ្យា ប៉ុន្តែពុំមានជំរៅដូចចិត្តវិទ្យារបស់ព្រះពុទ្ធសាសនាឡើយ ។ ពុទ្ធសាសនាសិក្សាអំពីចិត្តដោយផ្ទាល់តែម្តង ចំណែកក្រុមវិទ្យាសាស្ត្រពុំដូច្នេះទេ គេសិក្សាអំពីចិត្ត ដោយពិនិត្យមើលអាកប្បកិរិយាខាងក្រៅ ទើបគេដឹងថា ចិត្តមានសភាពយ៉ាងណា ដូចជាមនុស្សមានទឹកមុខញញឹមឬសើច គេថាមនុស្សនោះមានចិត្តសប្បាយ ។ បើមនុស្សមានទឹកមុខស្រងូតស្រងាត់ឬទឹកមុខក្រៀមក្រម គេថាមនុស្សនោះមានការព្រួយចិត្ត ។ បើមនុស្សមានទឹកមុខឡើងក្រហម មានអាការៈច្រងេងច្រងាង គេថាមនុស្សនោះមានចិត្តក្រោធខឹង ។ ប៉ុន្តែការដឹងចិត្តរបៀបនេះ អាចភ័ន្តច្រឡំឬខុសតែម្តង ព្រោះជួនកាលចិត្តនិងអាការៈខាងក្រៅពុំស្របគ្នា គឺជាការបញ្ចេញ

ដោយក្លែងបន្លំ ដូចជាមនុស្សខឹងតែធ្វើជាសើច មនុស្សសប្បាយចិត្តតែធ្វើមុខដូចជាខឹង ។ ដូច្នេះការទាយចិត្ត ដោយមើលអាការៈខាងក្រៅបែបនេះ ពុំត្រឹមត្រូវតាមការពិតទាំងអស់ឡើយ ហើយពុំដឹងថា ហេតុដូចម្តេចបានជាចិត្តកើតឡើងដូច្នេះ ចំណែកព្រះពុទ្ធសាសនាដឹងសភាពចិត្តបែបណាៗទាំងអស់ ។

ព្រះពុទ្ធសាសនានិយាយទាំងផ្នែករូបទាំងផ្នែកចិត្ត ទាំងលោកិយសច្ចទាំងលោកុត្តរសច្ចនិងបរមត្ថសច្ច ។ អត្ថរបស់អភិធម្មនិយាយពីចិត្ត ចេតសិក រូប និងនិព្វាន ។ ផ្នែករូបនិយាយអំពីរចនាសម្ព័ន្ធនៃរូប គឺកើតអំពីមហាភូត៤ គឺធាតុទឹក ធាតុដី ធាតុភ្លើង និងធាតុខ្យល់ និងឧបាយរូប គឺរូបផ្សំ២៤ទៀតមានបសាទ៥ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយជាដើម ។ ព្រះពុទ្ធជាម្ចាស់ជ្រាបផ្លូវចិត្ត ដោតញាណទស្សនៈ គឺដឹងនូវបុព្វចរិយា ការប្រព្រឹត្តនិងនិស្ស័យសន្តានរបស់មនុស្សសត្វ ពីដើមមកមានសភាពយ៉ាងណា ព្រះអង្គជ្រាបយ៉ាងនោះ ពុំមែនទាយចិត្តដោយមើលអាកប្បកិរិយាដូចអ្នកវិទ្យាសាស្ត្រឡើយ ។ នៅក្នុងគម្ពីរអភិធម្ម ចិត្តពីកំណើតគ្មានទេ ចិត្តកើតមានដោយភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងមនោប៉ះអាយតនៈខាងក្រៅ គឺរូប សម្លេង ក្លិន រស សម្ផស្ស និងធម្មា (គឺអារម្មណ៍ដែលចិត្តតោង) តើបកើតចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជីវ្ហាវិញ្ញាណ, កាយវិញ្ញាណ និងមនោវិញ្ញាណ ។ ទំរាំកើតចិត្តវិញ្ញាណ ត្រូវប្រព្រឹត្តទៅជាច្រើនខណៈចាប់ពីភវង្គមក។រូបនិងចិត្តត្រូវអាស្រ័យគ្នាទៅវិញទៅមក ទើបប្រព្រឹត្តទៅបាន ។ ក្នុងន័យទូទៅថា អ្វីមួយកើតឡើងត្រូវអាស្រ័យហេតុបច្ច័យផ្សំគ្នាដែលហៅថាសង្ខារ ហើយវាតាំងនៅនិងរលត់ទៅវិញ តាមកំរឹតកម្លាំងធាតុ នេះជាច្បាប់ធម្មជាតិដែលព្រះសម្ពុទ្ធត្រាស់ដឹង គឺវាមានហេតុផលក្នុងខ្លួនរបស់វា គ្មានព្រះជាម្ចាស់អង្គណាបង្កើតឡើងឡើយ ។ ពាក្យថា លោកិយសច្ច គឺពិតតាមលោកវោហារសន្មត ដូចជាឈ្មោះមនុស្ស ឈ្មោះសត្វ ឈ្មោះរុក្ខជាតិផ្សេងៗជាដើម ដែលមនុស្សដាក់ឈ្មោះ ដើម្បីស្រួលចំណាំកុំឲ្យច្រឡំគ្នា បុំមែនការពិតនៅត្រង់ឈ្មោះនោះឡើយ ដូចជាមនុស្សឈ្មោះសុខ ពុំមែនបានន័យថាមនុស្សនោះគ្មានទុក្ខឡើយ ។ ឯបរមត្ថសច្ច ដាក់ត្រូវពិតទៅតាមពិត ដូចបញ្ញត្តិថា រូបបានដល់ធម្មជាតិដែលកើតឡើងតែងវិនាសទៅវិញ ដោយក្តៅនិងត្រជាក់ជាដើម ហៅថារូប ។ ធម្មជាតិដែលចេះនឹកចេះគិត ហៅថាចិត្តជាដើម ។ ព្រះពុទ្ធសំដែងថា សេចក្តីសុខរបស់មនុស្សពុំមែនស្ថិតនៅលើសម្ភារៈតែម៉្យាងទេ គឺត្រូវស្ថិតនៅលើផ្លូវចិត្តជាសំខាន់ គឺចិត្តជាអ្នកប្រើប្រាស់សម្ភារៈ បើរបស់អ្វីមួយប្រែប្រួលកុំកើតទុក្ខផ្លូវចិត្ត ព្រោះអ្វីទាំងអស់ពុំទៀងទេ ។ បើមានសម្ភារៈ កីទ្រព្យសម្បត្តិច្រើន តែគេកើតទុក្ខផ្លូវចិត្តដោយសារមានវិបត្តិអ្វីមួយ នោះគេពុំបានសេចក្តីសុខឡើយ ។ ហេតុផលរបស់ព្រះពុទ្ធសំដែងថា សេចក្តីសុខកើតពីការស្ងប់ មានសេចក្តីស្ងប់ដោយការមិនបៀតបៀនគ្នាជាដើម ហើយស្ងប់ខ្ពស់បំផុត គឺស្ងប់របស់ព្រះនិព្វាន ដោយកាត់ផ្តាច់នូវឫសគល់ដែលនាំឲ្យសាងបាបកម្មទាំងអស់ ។

ព្រះពុទ្ធសំដែងថា អ្វីទាំងអស់ដែលកើតពីគ្រឿងផ្សំ «សង្ខារ» ពាក្យមួយម៉ាត់នេះ ទុកជាមូលដ្ឋានរបស់វិទ្យាសាស្ត្រ ទោះបីព្រះអង្គពុំបានសំដែងអំពីធាតុនេះផ្សំគ្នាទៅកើតជាធាតុនោះក៏ដោយ ក៏ព្រះអង្គពិតជាបានជ្រាបខាងវិទ្យាសាស្ត្រ ប៉ុន្តែព្រះអង្គបានទុកមុខងារនេះ ឲ្យក្រុមវិទ្យាសាស្ត្រស្រាវជ្រាវទៅទៀតចុះ ព្រះអង្គគ្រាន់តែផ្តាំថា បើក្រុមវិទ្យាសាស្ត្រចង់បង្កើតអ្វីក៏បង្កើតទៅចុះ ដើម្បីបំរើសេចក្តីសុខដល់សង្គមមនុស្ស កុំបង្កើតគ្រឿងសាស្ត្រាវុធយកទៅសម្លាប់គ្នា ដែលពាក្យផ្តាំនេះមានថែងក្នុងជំនួញខុស៥យ៉ាង មានមិនឲ្យផលិតមិនឲ្យធ្វើជំនួញគ្រឿងសាស្ត្រាវុធគ្រប់ប្រភេទ ព្រោះឲ្យនាំឲ្យយកទៅសម្លាប់គ្នា ។ បេសកកម្មរបស់ព្រះអង្គសំដែងធម៌ដើម្បីរំលត់ទុក្ខរបស់មនុស្សសត្វ ។ ធម៌នេះគឺអរិយសច្ច៤ បានដល់ទុក្ខសច្ច សេចក្តីទុក្ខបានដល់ការកើតឡើងនៃខន្ធ៥ ត្រូវកំណត់ដឹង, ហេតុដែលនាំឲ្យកើតទុក្ខ បានដល់បញ្ញាត្រូវលះបង់, ការរំលត់ទុក្ខ បានដល់ព្រះនិព្វន ត្រូវធ្វើឲ្យជាក់ច្បាស់, ផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ ត្រូវចំរើនឲ្យកើតឡើង ។៚